THE SCHOOL DISTRICT OF PHILADELPHIA

# សខស-ការពិនិត្យឡើងវិញនូវផែនការរបស់សាលា





ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា មានចក្ខុវិស័យច្បាស់លាស់មួយ៖ សម្រាប់ឱ្យក្មេងទាំងអស់មានលទ្ធភាពទៅរៀននៅសាលាមួយដែលល្អ នៅជិតកន្លែងដែលពួកគេរស់នៅ។ ដើម្បីសម្រេចចក្ខុវិស័យនេះ ចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះឆ្នាំ ២០១៩ ក្រសួងនឹងសហការជាដៃគូជាមួយអ្នកជំនាញដើម្បីឱ្យពួកគេដឹកនាំការពិនិត្យឡើងវិញនូវផែនការរបស់សាលាជាច្រើនឆ្នាំ (CSPR) ដែលគេបានបង្កើតឡើងដើម្បីប្រើវិធីសាស្ត្រជាប្រព័ន្ធ ក្នុងការពិនិត្យមើលការប្រែប្រួលនៃស្ថានភាព ប្រជាជន និង សហគមន៍ នៅទូទាំងទីក្រុងរបស់យើង ដែលគេបានធ្វើការសន្និដ្ឋានទុកសម្រាប់ឆ្នាំខាងមុខៗ។

### ១. តើអ្វីទៅដែលជា គោលដៅ និង លទ្ធផលនៃការរំពឹងទុក នៃការងារនេះ?

គោលដៅរួម គឺសម្រាប់ឱ្យក្រសួងរៀបចំសាលានៅគ្រប់តំបន់ទាំងអស់ ដើម្បីបំពេញតាមតម្រូវការនៃការអប់រំ ទៅតាមការផ្លាស់ប្តូរនៃស្ថានភាពប្រជាជន ដោយ៖

- បង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់អាគាររបស់យើង ដើម្បីធ្វើយ៉ាងណាឱ្យសិស្សអាចរៀននៅសាលាដែលមានគុណភាពខ្ពស់ ដែលនៅជិតកន្លែងដែលពួកគេរស់នៅ
- ចំណាយប្រាក់លើអ្វីដែលជាសេចក្តីត្រូវការខ្លាំងបំផុត
- បង្កើតការផ្លាស់ប្តូរប្រកបដោយការគិតគូរយ៉ាងច្បាស់លាស់ សម្រាប់សិស្សថ្នាក់ បឋមសិក្សា និង អនុវិទ្យាល័យ

### ២. តើកិច្ចការនេះមានពាក់ព័ន្ធនឹងសាលារបស់ខ្ញុំដែរឬទេ?

សាលារបស់ក្រសួងទាំងអស់ត្រូវបានគេដាក់បញ្ចូលនៅក្នុងផែនការនេះ។ សាលាទាំងអស់ត្រូវបានគេបែងចែកជាក្រុមៗ នៅក្នុងវេនណាមួយក្នុងចំណោមវេនទាំងបួន។ វេននៃការពិនិត្យឡើងវិញ នឹងចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះនៃឆ្នាំនីមួយៗ។ សាលាឆាទ័រមិននៅក្នុងដំណើរការនៃការពិនិត្យឡើងវិញនេះទេ។

### ៣. តើកិច្ចការនេះនឹងចាប់ផ្តើមនៅពេលណា?

វេនទីមួយចាប់ផ្តើមនៅរដូវស្លឹកឈើជ្រុះនៃឆ្នាំ ២០១៩។

### ៤. តើខ្ញុំអាចដឹងថាសាលារបស់ខ្ញុំនៅក្នុងវេនណានៃការពិនិត្យឡើងវិញ?

បញ្ជីនៃសាលាទាំងអស់ទៅតាមវេន អាចរកបាននៅក្នុងទំព័រវ៉ិបសៃរបស់ CSPR៖ www.philasd.org/cspr

### ៥. តើក្រសួងសម្រេចបែងចែកសាលាទាំងអស់ជាក្រុម សម្រាប់វេននីមួយៗដោយវិធីណា?

សាលានៅក្នុងតំបន់ទាំងអស់របស់យើង សំខាន់ណាស់។ យើងបែងចែកសាលាជាក្រុម ដោយគិតពីលក្ខណៈមួយចំនួន រួមទាំង៖

- ទីតាំង និង ចម្ងាយជិតៗគ្នា
- ការដឹងអំពីលក្ខណៈប្រែប្រួលនៃការចុះឈ្មោះចូលរៀន និង
- ផែនការដែលមានស្រាប់ អំពីថវិកាសម្រាប់ចំណាយ។

### ៦. តើហេតុអ្វីបានជា CSPR ត្រូវចំណាយពេលជាច្រើនឆ្នាំ ដើម្បីបញ្ចប់កិច្ចការនេះ?

ប្រភេទនៃផែនការនេះ ត្រូវការពេលវេលា ហើយយើងមានសាលាច្រើន សាលានៅតាមតំបន់ជាច្រើន មានបញ្ហាផ្ទាល់រៀងៗខ្លួន។ យើងត្រូវធ្វើកិច្ចការនេះដោយប្រុងប្រយ័ត្ន។ ហេតុដូច្នេះ យើងបានបែងចែកសាលាទៅជាតំបន់សិក្សាតូចៗ ក្នុងចំណោមវេនទាំងបួន ដើម្បីផ្តល់ការយកចិត្តទុកដាក់ ទៅតាមតម្រូវការនៃក្រុមនីមួយៗ។

ក្នុងចំណោមមូលហេតុផ្សេងៗទៀត ជាពិសេសយើងមានការប្តេជ្ញាចិត្ត ក្នុងការផ្តល់ឱ្យសហគមន៍សាលាចូលរួមការពិភាក្សាដ៏សំខាន់អំពីការសម្រេចចិត្តដែលប៉ះពាល់ដល់សាលារបស់ពួកគេ និង ធានាថាសម្លេងរបស់ ឪពុកម្តាយ និង សហគមន៍ បានបង្ហាញយ៉ាងច្បាស់នៅក្នុងអនុសាសន៍ចុងក្រោយ ដែលត្រូវបានគេផ្តល់ឱ្យគណៈកម្មការអប់រំដើម្បីអនុម័ត។ ហេតុដូច្នេះ ពេលវេលាបានឆ្លុះបញ្ចាំងពីការរួមបញ្ចូលចំនួននៃអង្គប្រជុំ ជុំវិញការចូលរួមរបស់សហគមន៍។

### ៧. តើនេះគ្រាន់តែជាការផ្លាស់ប្តូរព្រំដែនរបស់សាលាតែប៉ុណ្ណោះទេអ្វី?

មិនមែនទេ។ មានកត្តាជាច្រើនដែលគេត្រូវពិចារណា និង មានដំណោះស្រាយជាច្រើនដើម្បីជ្រើសរើស គឺអាស្រ័យលើសេចក្តីត្រូវការ។ ឧទាហរណ៍ យើងរកឃើញថា ដំណោះស្រាយដ៏ល្អបំផុតគឺ ពង្រីក ឬ កាត់បន្ថយ កម្រិតថ្នាក់ សាងសង់កន្លែងបន្ថែម ចំណាយលើមធ្យោបាយប្រើប្រាស់កន្លែងដែលមានស្រាប់ឱ្យកាន់តែមានប្រសិទ្ធភាព បញ្ចូលកម្មវិធីជាមួយគ្នា ដើម្បីចែកគ្នាប្រើធនធាន ឬ ផ្លាស់កម្មវិធីទៅទីតាំងដែលស័ក្តសមជាងនេះ។ ជួនកាលការផ្លាស់ប្តូរព្រំដែនសាលាគឺជាការចាំបាច់ ប៉ុន្តែវាគ្រាន់តែជាជម្រើសមួយក្នុងចំណោមជម្រើសជាច្រើនតែប៉ុណ្ណោះ។

### ៨. តើនរណាជាអ្នកជួយក្នុងការពិនិត្យឡើងវិញនេះ?

យើងកំពុងជួលអ្នកជំនាញថ្នាក់ជាតិ ដើម្បីធ្វើការប៉ាន់ប្រមាណលើចំនួនសិស្សដែលក្រសួងនឹងបម្រើក្នុងរយៈពេល ១០ ឆ្នាំខាងមុខនេះ។ ព័ត៌មាននេះ រួមជាមួយទិន្នន័យស្តីពីការបង្ហាត់បង្រៀនរបស់សាលា និង គុណភាពនៃអាគារ នឹងត្រូវប្រើប្រាស់ដោយគណៈកម្មការរៀបចំផែនការ ដើម្បីផ្តល់អនុសាសន៍ដល់ អគ្គនាយក និង គណៈកម្មការអប់រំ។

### ៩. តើខ្ញុំអាចចូលរួមដោយវិធីណា?

វិធីពីរយ៉ាង។ តំបន់សិក្សានីមួយៗ នឹងមានគណៈកម្មការរៀបចំផែនការ ដែលមានអ្នកតំណាងមាតាបិតាពីរនាក់។ គណៈកម្មការទាំងនេះនឹងធ្វើការជាមួយបុគ្គលិករបស់ក្រសួង និង អ្នកពិគ្រោះយោបល់ ដើម្បី ផ្តល់យោបល់ និង ប្រាប់ពីសំណូមពរ ដែលគេនឹងប្រគល់ឱ្យគណៈកម្មការសាលា និង ផ្តល់ព័ត៌មានមកសហគមន៍ឱ្យបានដឹងវិញ។ បើសិនជាលោកអ្នកចង់បម្រើការនៅក្នុងគណៈកម្មការរៀបចំផែនការរបស់សាលាលោកអ្នក សូមទាក់ទងទៅនាយកសាលារបស់លោកអ្នក។

ប៉ុន្តែលោកអ្នកមិនចាំបាច់ធ្វើជាគណៈកម្មការ ដើម្បីអាចផ្តល់យោបល់នោះទេ។ ឪពុកម្តាយ និង សមាជិកសហគមន៍ ទាំងអស់ នឹងមានឱកាសជាច្រើន ដើម្បីចូលរួមអង្គប្រជុំផ្តល់ព័ត៌មាន នៅរៀងរាល់វេននៃការពិនិត្យឡើងវិញ ហើយក៏អាចផ្តល់សក្ខីកម្មនៅក្នុងអង្គប្រជុំស្តីពីសកម្មភាពរបស់គណៈកម្មការអប់រំ ប្រចាំខែផងដែរ។

### ១០. តើគេចាប់ផ្តើមអនុវត្តអនុសាសន៍ពីវេននីមួយៗ នៅពេលណា?

គណៈកម្មការអប់រំអនុម័តអនុសាសន៍នៅនិទាឃរដូវ ហើយនឹងមានប្រសិទ្ធិភាពមិនឆាប់ជាងរដូវស្លឹកឈើជ្រុះនៃឆ្នាំក្រោយ។ ឧទាហរណ៍ អនុសាសន៍ដែលគេបានអនុម័តនៅនិទាឃរដូវឆ្នាំ ២០២០ នឹងត្រូវគេអនុវត្តសម្រាប់ឆ្នាំសិក្សា ២០២១-២០២២។

### ១១. តើខ្ញុំអាចធ្វើយ៉ាងដូចម្តេចដើម្បីដឹងពីព័ត៌មានថ្មីៗទាំងនេះ?

យើងបានប្រមូលព័ត៌មានទាន់ពេលវេលាអំពី CSPR ទាំងអស់ រួមទាំងដំណើរការ និង ការកំណត់ពេលវេលា នៅក្នុងវិបសៃរបស់យើង www.philasd.org/CSPR គេនឹងផ្តល់ព័ត៌មានថ្មីៗជាទៀងទាត់ ពី កាលវិភាគនៃអង្គប្រជុំ និង របាយការណ៍នៃការរីកចម្រើន នៅពេលណាដែលមាន។ ហើយក៏មានអ៊ីម៉ែលនៅក្នុងវិបសៃសម្រាប់ឱ្យលោកអ្នកផ្ញើសំណួរបន្ថែម នៅពេលណាក៏បាន។ សមាជិកនៃក្រុមការងាររបស់យើងនឹងឆ្លើយតបទៅលោកអ្នកវិញឱ្យបានទាន់ពេលវេលា។